ក្រសួងបរិស្ថាន
Ministry of Environment

លេខ: ១៣៧/១២ ប្រ.ក ប.ស្ថ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០ ១២

ប្រកាស
ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "រលំទឹកខ្មៅទឹកស" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅភូមិរស្មី ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៨ ស្តីពីការតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
- បានឃើញលិខិតស្នើសុំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ"រលំទឹកខ្មៅទឹកស" ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០១២
- តាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋាន។

សម្រេច

ប្រការ១ : រៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិ "រលំទឹកខ្មៅទឹកស" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅភូមិរស្មី ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។

ប្រការ២ : សហគមន៍តំបន់ការពារធម្មជាតិ "រលំទឹកខ្ទៅទឹកស" ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព មានទំហំផ្ទៃដីចំនួន ១៣០៥ ហិចតា ដូចមានដែនទីជាឧបសម្ព័ន្ធ កំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកាត់ខាងក្រោម ៖

ចំណុច	X	Y	ចំណុច	X	Y
A	447293	1551403	G	453041	1548490
B	448485	1551384	H	451595	1548392
C	449798	1551371	I	450428	1548471
D	451097	1551332	J	449205	1548581
E	452392	1551301	K	448249	1549707
F	452698	1549993	L	447724	1550623

ប្រការ៣ : ការរៀបចំសហគមន៍តំបន់ការពារធម្មជាតি"រលំទឹកខ្ទៅទឹកស" នៃដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ហើយសហគមន៍ត្រូវមានលក្ខន្តិកៈ និងដែនការគ្រប់គ្រងស្របតាមច្បាប់ស្តីពី តំបន់ការពារធម្មជាតি។

ប្រការ៤ : អគ្គនាយករដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានកម្រងតំបន់ការពារធម្មជាតি"ស្ទឹងសែន" ប្រធានមន្ទីរបរិស្ថានខេត្តព្រះវិហារ នាយកដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព និង សហគមន៍តំបន់ការពារធម្មជាតি"រលំទឹកខ្ទៅទឹកស" ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ាម៉ារ
ឧត្តម.ជីវិទ្ធ

ចម្លងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-សាលាខេត្តព្រះវិហារ
-ដូចប្រការ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ផែនទីសហគមន៍តំបន់ការពារ[illegible]ជាតិ "រលំធីកឡោធីកស" ស្ថិតក្នុងដែនជម្រកស[illegible]ព្រៃគុលែន[illegible]

ភូមិសាស្ត្រភូមិរស្មី ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ



សញ្ញាស៍តាង

- ចំណុចនិយាមការ
- ទីតាំងសហគមន៍តំបន់ការពារធម្មជាតិ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង. អូរ
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន 1:50,000

0 1 2 Kilometers

Indian_1960_UTM_Zone_48N

Id	N	X	Y
1	A	447293	1551403
2	B	448485	1551384
3	C	449798	1551371
4	D	451097	1551332
5	E	452392	1551301
6	F	452698	1549993
7	G	453041	1548490
8	H	451595	1548392
9	I	450428	1548471
10	J	449205	1548581
11	K	448249	1549707
12	L	447724	1550623